# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ១០

LECTURE 10

## អធិបតេយ្យរដ្ឋ

STATE SOVEREIGNTY

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្តីផ្តើម
- ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ
    - សញ្ញាណទូទៅ
    - គោលការណ៍ឯករាជ្យ
    - គោលការណ៍សមភាពអធិបតេយ្យ
- ផ្នែកទី៣ អធិបតេយ្យ និងការកកើតរដ្ឋ
    - សញ្ញាណទូទៅ
    - អបគមន៍
    - ការបំបែករដ្ឋ
    - ការប្រមូលផ្តុំរដ្ឋ
    - ការចាកផុតអាណានិគម

# កម្មវត្ថុនៃមេរៀន

នៅក្នុងមេរៀនស្តីពី អធិបតេយ្យរដ្ឋ មានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពីៈ

- អ្វីទៅជាអធិបតេយ្យរដ្ឋ?
- សារៈសំខាន់នៃអធិបតេយ្យរដ្ឋ
- គោរពគោលការណ៍ធានានូវអធិបតេយ្យរបស់រដ្ឋ
- អធិបតេយ្យ និងការកកើតនៃរដ្ឋ

# ផ្នែកទី១ សេចក្ដីផ្ដើម

រដ្ឋនីមួយៗ លើផែនដីតែងតែកើតឡើងដោយមានធាតុផ្សំរបស់វាច្បាស់លាស់ ទន្ទឹមនឹងគ្នានេះដែរ រដ្ឋក៏ត្រូវមានផងដែរនូវអធិបតេយ្យ ដើម្បីជាស្ពានក្នុងការធ្វើទំនាក់ទំនងអន្តរជាតិប្រកបដោយភាពស្មើគ្នា។ នៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ក៏បានបញ្ញត្តិពីការធានាដល់អធិបតេយ្យរបស់រដ្ឋផងដែរ។

# ផ្នែកទី១ សេចក្ដីផ្ដើម

តើពាក្យថា អធិបតេយ្យ មានអត្ថន័យខ្លឹមសារយ៉ាងណា?

អធិបតេយ្យកើតចេញពីពាក្យ អធិប និងតេយ្យ។ អធិប គឺមានន័យថា ឥស្សរភាព ភាពជាធំ ឬ អំណាច ជាអាទ៍។ ចំពោះពាក្យ តេយ្យ មានន័យថា សេរី ឯករាជ្យ ជាអាទ៍។ ដូច្នេះពាក្យថា អធិបតេយ្យរដ្ឋ គឺអំណាចរបស់រដ្ឋជាធំ។

# ផ្នែកទី១ សេចក្តីផ្តើម

អធិបតេយ្យរដ្ឋ គឺជាគោលការណ៍ដែលរដ្ឋមួយមិនស្ថិតនៅក្រោយអំណាចនៃរដ្ឋ ឬអាជ្ញាធរណាមួយឡើយ ហើយនេះគឺជាគោលការណ៍នៃអំណាចផុតលេខរបស់រដ្ឋ ក្នុងសម្រេចនូវកិច្ចការទាំងឡាយដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលរួមមានអំណាចក្នុងជ្រើសរើសប្រព័ន្ធគ្រប់គ្រងជាអាទិ៍។

# ផ្នែកទី១ សេចក្តីផ្តើម

គេអាចសម្គាល់ពីអធិបតេយ្យរដ្ឋបានតាមរយៈ ឯករាជ្យជាតិរបស់រដ្ឋនោះ ដែលពាក្យអធិបតេយ្យ និងឯករាជ្យ គឺផ្សាភ្ជាប់គ្នា។ អធិបតេយ្យ គឺជាមហាកំផែងសម្រាប់ការពារគ្រឹះនៃរដ្ឋក៏ជាការពារនូវគ្រឹះនីតិអន្តរជាតិផងដែរ។ តើគេអាចការពារនូវអធិបតេយ្យយ៉ាងដូចម្តេច?។

# ផ្នែកទី១ សេចក្តីផ្តើម

ការដាក់បំរាមហាមមិនឲ្យមានការជ្រៀតជ្រែក ចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋ គឺជាមធ្យោបាយមួយដើម្បីការពារនូវអធិបតេយ្យរដ្ឋ ប្រសិនបើមានការជ្រៀតជ្រែកកើតឡើង វាគឺជាបទល្មើសដែលអាចនាំឲ្យមានការដាក់ទណ្ឌកម្ម។ ទោះជាមានបំរាមក៏ដោយ ក៏គេសង្កេតឃើញថា នៅតែមានការជ្រៀតជ្រែកកើតឡើង។

# ផ្នែកទី១ សេចក្ដីផ្ដើម

នៅក្នុងមេរៀន អធិបតេយ្យរដ្ឋនេះ យើងនឹងធ្វើការសិក្សាពីខ្លឹមសារនៃអធិបតេយ្យរដ្ឋ (ផ្នែកទី២) ហើយនឹងសិក្សាផងដែរពីអធិបតេយ្យ និងការកកើតនៃរដ្ឋ (ផ្នែកទី៣) និងចុងបញ្ចប់ អធិបតេយ្យ និងការទទួលរដ្ឋ (ផ្នែកទី៤)។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- សញ្ញាណទូទៅ

រដ្ឋមួយ នៅពេលដែលកើតឡើងត្រូវមានធាតុផ្សំចំនួន៣ គឺ ទឹកដី ប្រជាជន និងរដ្ឋាភិបាល។ ទន្ទឹមនឹងគ្នានេះដែរ រដ្ឋក៏ត្រូវមានផងដែរនូវអធិបតេយ្យ គឺត្រូវមានផងដែរនូវសិទ្ធិអំណាចក្នុងការធ្វើទំនាក់ទំនងជាមួយរដ្ឋដ៏ទៃទៀត។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- សញ្ញាណទូទៅ

ដូច្នេះ អធិបតេយ្យរដ្ឋជាធាតុមួយដ៏សំខាន់ផងដែរ ដើម្បីអាចឲ្យរដ្ឋដំណើរការទៅបានដោយរលូន ដូចជាការបង្កើតច្បាប់ ឬ បទដ្ឋានទាំងឡាយដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងកិច្ចការរដ្ឋ (អំណាចគ្រប់គ្រងផ្ទៃក្នុង និងខាងក្រៅ)។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- សញ្ញាណទូទៅ

សូមបញ្ជាក់ថា មានតែរដ្ឋទេដែលអាចគេចផុតពីអន្តរាគមន៍របស់អ្នកដ៏ទៃដោយប្រើខែលអធិបតេយ្យ ហើយអន្តរាគមន៍នោះអាចអនុវត្តទៅបាន លុះណាមានការផ្តល់ការយល់ព្រមពីរដ្ឋ។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- សញ្ញាណទូទៅ

ដោយសារតែអធិបតេយ្យរដ្ឋនេះហើយ ដែលអាចឲ្យរដ្ឋមានសេរីភាពពេញលេញ និងទូលំទូលាយក្នុងការសម្រេចជ្រើសរើសនូវទម្រង់គ្រប់គ្រងរដ្ឋរបស់ខ្លួនដូចមានចែងនៅក្នុងច្បាប់កំពូលរបស់ខ្លួន ដែលគេហៅថារដ្ឋធម្មនុញ្ញ ហើយដែលទម្រង់នៃការគ្រប់គ្រងរដ្ឋមានច្រើន។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

• សញ្ញាណទូទៅ

អ្នកសិក្សាគួរចង់ចាំផងដែរថា នីតិអន្តរជាតិមានអាត្កិភាពទៅបាន ក៏ដោយសារតែរដ្ឋដែលមានអធិបតេយ្យមានឆន្ទៈក្នុងការប្រព្រឹត្តិបត្តច្បាប់អន្តរជាតិ។ អធិបតេយ្យរដ្ឋ អាចស្តែងឡើងដោយគោលការណ៍ឯករាជ្យ និងសមភាពរវាងអធិបតេយ្យ។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- គោលការណ៍ឯករាជ្យ

ឯករាជ្យរដ្ឋ ឬ ឯករាជ្យជាតិ គឺជាសិទ្ធិ និងសេរីភាពពេញលេញរបស់រដ្ឋ ក្នុងការគ្រប់គ្រងខ្លួនឯង ដោយខ្លួនឯង មិនស្ថិតនៅក្រោមអំណាចនៃរដ្ឋណាមួយ ឬ អង្គការអន្តរជាតិណាមួយឡើយ។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- គោលការណ៍ឯករាជ្យ

គោលការណ៍ ជាលក្ខវិនិច្ឆ័យដើម្បីសម្គាល់ថា រដ្ឋមួយមានអធិបតេយ្យ ឬ ពុំមាន។ ពាក្យថាអធិបតេយ្យ និងឯករាជ្យគឺមានន័យបំពេញឲ្យគ្នាទៅវិញទៅមក ឬ អាចនិយាយបានថាវាមានន័យសមមូលគ្នា។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- គោលការណ៍ឯករាជ្យ

លោកអ៊ុយប៉ែរ បានលើកឡើងថា អធិបតេយ្យក្នុងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ គឺឯករាជ្យ។ នៅក្នុងយុត្តិសាស្ត្រអន្តរជាតិក៏បានលើកឡើងនូវសញ្ញាណទាំងពីរនេះមានតម្លៃដូចគ្នាផងដែរ។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- គោលការណ៍ឯករាជ្យ

ឯករាជ្យដែលយើងនិយាយនៅទីនេះ ពោលគឺសំដៅដល់អំណាចរដ្ឋដែលមិនស្ថិតនៅក្រោមបញ្ជារបស់គេ តែមិនមែនមានន័យថា មិនអាស្រ័យទាក់ទងជាមួយរដ្ឋដ៏ទៃទៀតទេ ព្រោះថារដ្ឋមិនអាចរស់នៅដោយឯកកោនោះឡើយ។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- គោលការណ៍ឯករាជ្យ

កុំមានការភាន់ច្រឡំថា អង្គការអន្តរជាតិគឺជាអាជ្ញាធរថ្នាក់លើរបស់រដ្ឋឡើយ ព្រោះមានតែរដ្ឋទេដែលមានអធិបតេយ្យ និងជាអ្នកចូលរួមក្នុងការបង្កើតអង្គការអន្តរជាតិ ដែលកើតចេញពីឆន្ទៈរួមគ្នាដើម្បីសម្រេចនូវគោលដៅរួមអ្វីមួយ។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- គោលការណ៍ឯករាជ្យ

ដូច្នេះ គោលការណ៍ឯករាជ្យ គឺគ្មានអ្វីអាចធ្វើអន្តរាគមន៍ចូលទៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋបានទេ ពោលគ្មានរដ្ឋណាមួយអាចបង្ខំរដ្ឋមួយទៀតឲ្យធ្វើការបញ្ជារបស់ខ្លួន ហើយត្រូវតែចាត់ទុករដ្ឋផ្សេងមានសិទ្ធិអំណាចស្មើនឹងខ្លួនដែរ។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- គោលការណ៍សមភាពអធិបតេយ្យ

រដ្ឋអធិបតេយ្យ អាចចុះកិច្ចព្រមព្រៀង ឬ សន្ធិសញ្ញាជាមួយរដ្ឋដ៏ទៃទៀតបាន ដោយពុំរដ្ឋដ៏ទៃរខាន ឬ រារាំងខ្លួនបានឡើយ ដូច្នេះសមត្ថភាពក្នុងការចុះកិច្ចព្រមព្រៀង គឺជាកេតនភណ្ឌនៃអធិបតេយ្យរដ្ឋ។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- គោលការណ៍សមភាពអធិបតេយ្យ

មាត្រា២.១ នៃធម្មនុញ្ញារបស់អង្គការសហប្រជាជាតិ បានបញ្ញត្តិថា អង្គការនេះត្រូវបានបង្កើតឡើងដោយឈរលើគោលការណ៍សមភាពអធិប័តេយ្យ រវាងរដ្ឋដែលជាសមាជិករបស់ខ្លួនទាំងអស់។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- គោលការណ៍សមភាពអធិបតេយ្យ

ក្នុងក្របខណ្ឌទំនាក់ទំនងអន្តរជាតិ រដ្ឋ និងរដ្ឋមានសមភាពអធិបតេយ្យរវាងគ្នានឹងគ្នា ដោយពុំគិតពីទំហំ សមត្ថភាព ឬជារដ្ឋអ្នកមាន ឬ ក្រនោះឡើយ។ ប៉ុន្តែ អ្វីដែលជាការព្រួយបារម្ភណ៍នោះ គឺត្រូវពិចារណាអំពីវិសមភាពផងដែរ។

# ផ្នែកទី២ ខ្លឹមសារនៃអធិបតេយ្យរដ្ឋ

- គោលការសមភាពអធិបតេយ្យ

រដ្ឋទាំងអស់មានសិទ្ធិ និងកាតព្វកិច្ចអន្តរជាតិដូចៗគ្នា គឺថាមានសមភាពចំពោះនីតិអន្តរជាតិ និងចំពោះរដ្ឋនិងរដ្ឋផង។ គេមិនអាចបង្ខំឲ្យរដ្ឋណាមួយទទួលយក ឬ មិនទទួលយកបទដ្ឋានណា ឬ របបនយោបាយណាមួយនោះឡើយ។

# ផ្នែកទី៣ អធិបតេយ្យ និងការកកើតរដ្ឋ

- សញ្ញាណទូទៅ

ដូចដែលបានសិក្សារួចមកហើយនៅក្នុងមេរៀនទី៨ រដ្ឋអាចកើតឡើងដោយធាតុផ្សំចំនួន៣ និងដំណើនៃការកកើតរដ្ឋអាចមានទម្រង់ ឬ រូបភាពផ្សេងៗគ្នា ប៉ុន្តែរដ្ឋមិនអាចខ្វះបាននូវអធិបតេយ្យ។

# ផ្នែកទី៣ អធិបតេយ្យ និងការកកើតរដ្ឋ

- សញ្ញាណទូទៅ

រដ្ឋអាចកកើតឡើង តាមរយៈការបង្កើតឲ្យមាននូវអង្គការនយោបាយមួយនៅលើទឹកដី ដោយប្រើប្រាស់ការកាន់ជាក់ស្ដែង ឬ ដោយការដោតទង់ជាតិរបស់ខ្លួនមុនគេនៅលើទឹកដីដែលគ្មានម្ចាស់។ បច្ចុប្បន្ន ទឹកដីគ្មានម្ចាស់គឺគ្មានទេ។

# ផ្នែកទី៣ អធិបតេយ្យ និងការកកើតរដ្ឋ

- សញ្ញាណទូទៅ

ដូច្នេះការបង្កើតរដ្ឋថ្មី អាចកើតឡើងក្រោមរូបភាពដូចជា ការកកើតដោយការធ្វើ អបគមន៍ ឬ ការបំបែករដ្ឋចេញពីគ្នាចំពោះរដ្ឋមួយដែលមានស្រាប់ ឬ ការប្រមូលផ្តុំនៃរដ្ឋច្រើនទៅជារដ្ឋសហព័ន្ធមួយថ្មី ឬ ការកើតដោយសារការចាកផុតពីនឹមអាណានិគមន៍។

# ផ្នែកទី៣ អធិបតេយ្យ និងការកកើតរដ្ឋ

- អបគមន៍

ជាការធ្វើឲ្យចំណែកណាមួយនៃទឹកដី ឬ ប្រជាជន ដែលរស់នៅក្នុងរដ្ឋណាមួយដែលមានស្រាប់ ទាមទារបង្កើតនូវរដ្ឋឯករាជ្យថ្មី ចេញពីរដ្ឋចាស់។ អបគមន៍ បានធ្វើឲ្យប៉ះពាល់ដល់គោលការណ៍បូរណភាពទឹកដីរបស់រដ្ឋ ដែលនាំឲ្យសហាគមន៍អន្តរជាតិមិនទទួលយកបានឡើយ។

# ផ្នែកទី៣ អធិបតេយ្យ និងការកកើតរដ្ឋ

- អបគមន៍

សូមចង់ចាំថា អបគមន៍ គឺជាកិច្ចផ្ទៃក្នុងរបស់រដ្ឋ លើកលែងតែមានជម្លោះយោធា ដែលប៉ះពាល់ដល់សន្តិសុខជាអន្តរជាតិ ទើបមានអន្តរាគមន៍ពីខាងក្រៅ។ ដូច្នោះហើយ ទើបការធ្វើអបគមន៍នៅតែជាមធ្យោបាយមួយក្នុងបង្កើតរដ្ឋថ្មី។

# ផ្នែកទី៣ អធិបតេយ្យ និងការកកើតរដ្ឋ

- អបគមន៍

គួរគត់សម្គាល់ថា រហូតមកដល់បច្ចុប្បន្ននេះ សហាគមន៍អន្តរជាតិពុំហ៊ានទទួលស្គាល់រដ្ឋដែលកើតចេញពីការធ្វើអបគមន៍ ឬ លើកទឹកចិត្តឲ្យមានការបំបែកទឹកដីតាមការធ្វើអបគមន៍នោះទេ ព្រោះអាចប៉ះពាល់ដល់អធិបតេយ្យរដ្ឋ។

# ផ្នែកទី៣ អធិបតេយ្យ និងការកកើតរដ្ឋ

• ការបំបែករដ្ឋ

ជាការបែកចេញនូវរដ្ឋពីរដ្ឋដែលមានស្រាប់ ទៅជារដ្ឋឯករាជ្យថ្មីពីរ ឬ ច្រើននៅលើទឹកដីនៃរដ្ឋចាស់ ឧទាហរណ៍ ការបំបែករដ្ឋនៃអតិយតសហភាពសូវៀត កើតចេញនូវរដ្ឋថ្មីចំនួន១៥។ ជាទូទៅការបំបែករដ្ឋមិនប៉ះពាល់ធ្ងន់ធ្ងរដល់អធិបតេយ្យរដ្ឋទេ។

# ផ្នែកទី៣ អធិបតេយ្យ និងការកកើតរដ្ឋ

- ការប្រមូលផ្តុំរដ្ឋ

វាជាការច្របាច់ចូលគ្នានូវរដ្ឋច្រើន ឲ្យក្លាយជារដ្ឋឯករាជ្យថ្មីតែមួយ។ រដ្ឋដែលរួមគ្នានោះ នឹងក្លាយជាសមាជិករដ្ឋសហព័ន្ធថ្មី។ ឧទាហរណ៍ រដ្ឋច្រើនរួមបង្កើតបានជាសហរដ្ឋអាមេរិកនៅឆ្នាំ១៨៧០ ជាអាទិ៍។

# ផ្នែកទី៣ អធិបតេយ្យ និងការកកើតរដ្ឋ

- ការចាកផុតអាណានិគម

ជាមធ្យោបាយបង្កើតរដ្ឋថ្មីនៅចុងសតវត្សទី១៩ និងដើមសតវត្សទី២០ នៅពេលនោះហើយដែលគោលការណ៍សញ្ជាតិ និង សិទ្ធិស្វ័យសម្រេចត្រូវបានដាក់បញ្ចូលទៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

# ផ្នែកទី៣ អធិបតេយ្យ និងការកកើតរដ្ឋ

- ការចាកផុតអាណានិគម

គោលការណ៍ទាំងនេះ បានជម្រុញឲ្យប្រជាជនដែលស្ថិតនៅក្រោមការត្រួតត្រា ជិះជាន់ នឹងធ្វើទុកបុកម្នេញពីម្ចាស់អាណានិគមបានងើបឈរឡើង រំដោះខ្លួនចេញពីការគៀបសង្កត់បង្កើតបានរដ្ឋឯករាជ្យ។ តើការកកើតនៃរដ្ឋតាមរូបភាពទាំងនេះ នាំឲ្យប៉ះពាល់ដល់អធិបតេយ្យរដ្ឋដែរ ឬទេ?

# ផ្នែកទី៣ អធិបតេយ្យ និងការកើតរដ្ឋ

ប្រាកដហើយ គ្រប់ទម្រង់ ឬ រូបភាពនៃការកើតនៃរដ្ឋថ្មីអាច នាំឲ្យមានផលប៉ះពាល់ដល់អធិបតេយ្យរដ្ឋ គ្រាន់តែរូបភាព មួយចំនួនមិនសូវប៉ះពាល់ខ្លាំង ហើយរូបភាពមួយចំនួន ទៀតនាំឲ្យមានការប៉ះពាល់ខ្លាំង ដូចជាការបង្កើតរដ្ឋថ្មីតាម រយៈការធ្វើអបគមន៍ ជាដើម។

មេរៀនទី១០ ស្តីពីអធិបតេយ្យរដ្ឋ បានបញ្ចប់។ សូមអរគុណសម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។